គោលការណ៍ និងសិទ្ធិសេរីភាពទាំង១០ប្រការស្តីអំពីអ៊ីនធឺណិត

ឯកសារនេះ ត្រូវបានដកស្រង់ចេញមកពីឯកសារមូលដ្ឋានដែលមាន១០ប្រការជាគោលសំខាន់ៗនៃការគ្រប់គ្រងលើវិស័យអ៊ីនធឺណិត។ ប្រការទាំងនោះត្រូវបានធ្វើការកែប្រែនិងដកស្រង់ដោយ the Internet Rights and Principles Dynamic Coalition (IRP) ដែលជាបណ្តាញបើកចំហរមួយរវាងបណ្តាមនុស្ស និងអង្គការនានាដែលកំពុងធ្វើការលើគម្រោងគាំទ្រសិទ្ធិរបស់អ្នកប្រើប្រាស់នៅក្នុងបរិស្ថាននៃអ៊ិនធឺណិត។

គោលការណ៍ទាំងនោះគឺជាឬសគល់នៃស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ដែលបានដកស្រង់ចេញពីការរួមគ្នារវាងគណៈកម្មការសិទ្ធិមនុស្ស និងគោលការណ៍ច្បាប់ក្នុងការប្រើប្រាស់អ៊ិនធឺណិត។

អ៊ិនធឺណិតបានចូលរួមចំណែកផ្តល់នូវឱកាសដែលមិនធ្លាប់មានពីមុនមកសំរាប់តថភាពនៃសិទ្ធិមនុស្ស ព្រមទាំងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់យើងទាំងអស់គ្នា។ វាជារឿងសំខាន់ ដែលរាល់គ្រប់អ្នកប្រើប្រាស់អ៊ីនធឺណិតទាំងសាធារណៈ និងឯកជនត្រូវតែគោរព និងការពារសិទ្ធិរបស់ខ្លួននៅក្នុងវិស័យអ៊ិនធឺណិត។ កត្តាជាច្រើនត្រូវបានយកមកប្រើប្រាស់ដើម្បីធានាថាអ៊ិនធឺណិតត្រូវបានប្រតិបត្តិ និងមានទំនាក់ទំនងនៅក្នុងវិធីសាស្រ្តផ្សេងៗដែលបានបំពេញនូវការការពារសិទ្ធិមនុស្ស។ ដើម្បីជំរុញអោយមានការទទួលស្គាល់ចក្ខុវិស័យស្តីអំពីសិទ្ធិមូលដ្ឋាននៅក្នុងបរិស្ថាននៃវិស័យអ៊ីនធឺណិត យើងនឹងបង្ហាញពីគោលការណ៍ និងសិទ្ធិសេរីភាពក្នុងការប្រើប្រាស់អ៊ីនធឺណិតទាំង១០ចំណុចដូចជា ៖

**១. លក្ខណៈជាសាកល និង សមភាព**

គ្រប់បុគ្គលទាំងអស់ចាប់កំណើតឡើងជាមួយសេរីភាព និងភាពស្មើគ្នានៃសិទ្ធិ ព្រមទាំងសេចក្តីថ្លៃថ្នូរ ដែលត្រូវបានទទួលនូវការគោរព ការគាំពារ និង បំពេញនូវតំរូវការនៅក្នុងវិស័យអ៊ិនធឺណិត ។

**២. សិទ្ធិ និងយុត្តិធម៌នៅក្នុងសង្គម**

អ៊ិនធឺណិតគឺជាកន្លែងសំរាប់ធ្វើការផ្សព្វផ្សាយ គាំពារ និងការបំពេញតំរូវការនៃសិទ្ធិមនុស្ស ព្រមទាំង

ភាពជឿនលឿននៃយុត្តិធម៌នៅក្នុងសង្គម។ គ្រប់គ្នាមានកាតព្វកិច្ចគោរពសិទ្ធិគ្នាទៅវិញទៅមកនៅក្នុងវិស័យអ៊ិនធឺណិត។

**៣. ភាពដែលអាចដំណើរការបាន**

គ្រប់គ្នាមានសិទ្ធិស្មើគ្នាក្នុងការដំណើរការ និងប្រើប្រាស់អ៊ិនធឺណិតដោយបើកចំហរនិងសុវត្ថិភាព។

**៤. ការចូលរួម និងការបញ្ចេញមតិយោបល់**

មនុស្សគ្រប់រូបមានសិទ្ធិក្នុងការស្វែងរក ការទទួលបាន និង ផ្តល់ពត៌មានដោយសេរីនៅលើបណ្តាញអ៊ិនធឺណិតដោយគ្មានការត្រួតពិនិត្យ ឬការបង្អាក់ផ្សេងៗទៀត។

ហើយបុគ្គលម្នាក់ៗក៏មានសិទ្ធិក្នុងការចូលរួមដោយសេរីនៅលើបណ្តាញអ៊ិនធឺណិតសំរាប់ការចូលរួមក្នុងសង្គម នយោបាយ វប្បធម៌ ឬនៅក្នុងគោលបំណងផ្សេងៗទៀតផងដែរ។

**៥. សុវត្ថិភាពពត៌មាន និងឯកជនភាព**

មនុស្សទាំងអស់មានសិទ្ធិជាឯកជននៅលើបណ្តាញអ៊ិនធឺណិតដោយរួមបញ្ចូលសិទ្ធិសេរីភាពពីការតាមដាន សិទ្ធិក្នុងការប្រើប្រាស់ការបំប៉ែកទិន្នន័យទៅជាលេខកូដសំងាត់ និងសិទ្ធិក្នុងអនាមិកភាព។ ពួកគេក៏មានសិទ្ធិក្នុងការការពារទិន្នន័យដោយរួមបញ្ចូលទាំងការគ្រប់គ្រងលើការប្រមូលទិន្នន័យផ្ទាល់ខ្លួន ការរក្សាទុកទិន្នន័យ ដំណើរប្រតិបត្តិទិន្នន័យ ការលុបទិន្នន័យចោល និងការបង្ហាញទិន្នន័យទាំងនោះនៅលើបណ្តាញអ៊ិនធឺណិត ។

**៦. សន្តិសុខ សេរីភាព និងតថភាព**

សិទ្ធិទាំងនេះត្រូវទទួលបានការគោរព និងការពារនៅលើបណ្ដាញអ៊ិនធឺណិត ដែលមិនត្រូវបានជ្រៀតជ្រែក ពីសំណាក់បុគ្គលមួយចំនួន ឬត្រូវប្រើប្រាស់សំរាប់រំលោភលើសិទ្ធិរបស់អ្នកដទៃឡើយ។

## ៧. ភាពដោយឡែក

ភាពផ្សេងៗគ្នានៃវប្បធម៌ និង ភាសានៅលើបណ្ដាញអ៊ិនធឺណិតត្រូវបានលើកទឹកចិត្ត ហើយបច្ចេកវិទ្យា និងគោលនយោបាយថ្មីៗគប្បីទទួលបានការលើកទឹកចិត្តផងដែរ ដើម្បីសម្របសម្រួលទៅនឹងភាពដោយឡែកនៃទស្សនៈផ្សេងៗទាំងឡាយ។

## ៨. ភាពស្មើគ្នានៃបណ្ដាញ

មនុស្សទាំងអស់មានសិទ្ធិក្នុងដំណើរប្រតិបត្តិទៅលើមាតិកានៃបណ្ដាញអ៊ិនធឺណិត មានសេរីភាពពីការរើសអើង គ្រប់គ្រងលើចរាចរណ៍នៅក្នុងពាណិជ្ជកម្ម នយោបាយ រឺផ្នែកផ្សេងៗទៀត ។

## ៩. បទដ្ឋាន និង បញ្ញត្តិ

ស្ថាបត្យកម្មអ៊ិនធឺណិត ប្រព័ន្ធទំនាក់ទំនងផ្សេងៗ ឯកសារ និងទំរង់បែបបទទិន្នន័យផ្សេងៗគួរតែត្រូវបានផ្អែកលើមូលដ្ឋានបទដ្ឋានសាធារណៈដែលត្រូវបានធានានូវដំណើរកាប្រតិបត្តិ ការរួមបញ្ចូល និង ភាពស្មើគ្នានៃឱកាសសំរាប់បុគ្គលផងគ្នា។

## ១០. អភិបាលកិច្ច

សិទ្ធិមនុស្ស និង យុត្តិធម៌នៅក្នុងសង្គមត្រូវតែបង្កើតនូវគោលការណ៍បទដ្ឋាន និងស្របច្បាប់ទៅលើអ្វីដែលអ៊ិនធឺណិតដំណើរការប្រតិបត្តិ និងត្រូវបានគ្រប់គ្រ

ង ។ បញ្ហានេះគួរតែមានតំលាភាព និង មានរបៀបវារៈដែលមានលក្ខណៈពហុភាគីដោយផ្អែកលើគោលការណ៍បើកចំហរួមបញ្ចូលទាំងការចូលរួម និងទំនួលខុសត្រូវ ។

ចូលរួមក្នុងការអភិវឌ្ឍន៍ជាមួយគណៈកម្មការIRP តាមរយៈ [www.irpcharter.org](http://www.irpcharter.org)

ធ្វើការតាមដានពីសកម្មភាពរបស់គណៈកម្មការIRP តាមរយៈ @netrights នៅលើបណ្ដាញ Twitter ឬ ចូលរួមជាមួយក្រុម Internet Rights and Principles នៅលើបណ្ដាញ Facebook។